**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

TRUST REGULATOR
**និយ័តករបរធនបាលកិច្ច**
លេខ: ០០៧/២២ ន.ប.ធ./ស.ជ.ណ.

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិ ក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២

និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) មានកិត្តិយសសូមជូនដំណឹងដល់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិ សម្រាប់ក្រុមហ៊ុនបរធនបាល បរធនបាលរូបវន្តបុគ្គលឯករាជ្យ និងក្រុមហ៊ុនផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងសាធារណជនទាំងអស់ជ្រាបថា÷ **ន.ប.ធ.** នឹងរៀបចំការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុង វិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ ដោយបានបែងចែកបេក្ខជនទៅតាមក្រុម និងកាលបរិច្ឆេទដូចខាងក្រោម÷

❖ **ក្រុមទី១**
- **កាលបរិច្ឆេទ:** ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២
- **ទីកន្លែង:** នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ (CKCC)។

❖ **ក្រុមទី២**
- **កាលបរិច្ឆេទ:** ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២
- **ទីកន្លែង:** នៅសាលប្រជុំជាន់ទី២ នៃអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

❖ **ក្រុមទី៣**
- **កាលបរិច្ឆេទ:** ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២
- **ទីកន្លែង:** នៅសាលប្រជុំជាន់ទី២ នៃអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**សម្គាល់÷** ចំពោះរាល់ព័ត៌មានពាក់ព័ន្ធ និងលក្ខខណ្ឌនៃការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិ ក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ **ន.ប.ធ.** នឹងជូនដំណឹងលម្អិតនៅក្នុងវគ្គបណ្តុះបណ្តាល ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិ និងសាធារណជនទាំងអស់ជ្រាប ជាព័ត៌មាន។

ថ្ងៃ សុក្រ ៩ រោច ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២២
**និយ័តករបរធនបាលកិច្ច**

**លេខទំនាក់ទំនង**
-០៧៧ ២៧៨ ០១៩ (កញ្ញា ស៊ុន រដ្ឋី)
-០១១ ៧៦៦ ៦២៦ (កញ្ញា ពេញ ឈុនធី)
បញ្ជីឈ្មោះបេក្ខជនដែលត្រូវប្រឡង

អាសយដ្ឋាន : អគារ ១៦៨F (ជាន់ទី៨) សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address : Building 168F (8th Floor), Street 598, Sangkat Chrang Chamreh 1, Khan Russey Keo, Phnom Penh, Kingdom of Cambodia
ទូរសព្ទ : (+៨៥៥)២៣-២៣៧-៨៨៨
សារអេឡិចត្រូនិច : info@trustregulator.gov.kh
គេហទំព័រ : www.trustregulator.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករបរធនបាលកិច្ច
TRUST REGULATOR

និយ័តករបរធនបាលកិច្ច
លេខ: ០០៨/២២. និ.ប.ធ.

ថ្ងៃ ... ខែ ... ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២២ខែ កក្កដា ឆ្នាំ២០២២

# សេចក្តីណែនាំ

## ស្តីពី

## ការប្រឡងទទួលស្គាល់គុណវុឌ្ឍិដែលរៀបចំដោយនិយ័តករបរធនបាលកិច្ច

**សម័យប្រឡង ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ សម្រាប់ក្រុមទី ១**

**សម័យប្រឡង ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ សម្រាប់ក្រុមទី ២**

**សម័យប្រឡង ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ សម្រាប់ក្រុមទី ៣**

**ចាប់ពីម៉ោង ១០ : ០០ ដល់ ១១ : ៣០ ព្រឹក**

ក្នុងគោលបំណងរក្សាឱ្យបាននូវសណ្តាប់ធ្នាប់ របៀបរៀបរយ និងវិន័យក្នុងការប្រឡងទទួលស្គាល់គុណវុឌ្ឍិដែលរៀបចំដោយ **និ.ប.ធ.** បេក្ខជនទាំងអស់ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រឡងដូចខាងក្រោម÷

**១. វិន័យ**

**ក. បេក្ខជនត្រូវ÷**

- មកដល់មណ្ឌលប្រឡងឱ្យបាន ៣០ (សាមសិប) នាទីមុនការប្រឡងចាប់ផ្តើម
- បង្ហាញបណ្ណសម្គាល់ខ្លួនដូចជា÷ អត្តសញ្ញាណបណ្ណ សំបុត្រកំណើត លិខិតឆ្លងដែន បណ្ណបើកបរ ឬឯកសារផ្សេងៗទៀតដែលអាចបញ្ជាក់ពីអត្តសញ្ញាណរបស់បេក្ខជនមុនពេលចូលក្នុងបន្ទប់ប្រឡង
- ស្លៀកពាក់ឱ្យបានសមរម្យ
- ស្នើសុំការអនុញ្ញាតពីគណៈកម្មការជាមុន ករណីមានការចាំបាច់ត្រូវចេញពីបន្ទប់ប្រឡងក្នុងអំឡុងពេលប្រឡង
- គោរពតាមការណែនាំរបស់គណៈកម្មការ។

**ខ. បេក្ខជនមិនត្រូវ÷**

- យកសំណៅឯកសារ និងកំណត់ត្រាផ្សេងៗ ឬសម្ភារៈដទៃទៀតដូចជា អាវុធជាតិផ្ទុះ កុំព្យូទ័រ ឬឧបករណ៍អេឡិចត្រូនិកផ្សេងៗចូលបន្ទប់ ឬមណ្ឌលប្រឡងឡើយ **លើកលែងតែម៉ាស៊ីនគិតលេខ**
- ប្រើប្រាស់ទូរស័ព្ទ វិទ្យុទាក់ទងផ្សេងៗ ឬឧបករណ៍សម្រាប់ទំនាក់ទំនងផ្សេងទៀតក្នុងពេលប្រឡង
- ចូលបន្ទប់ប្រឡងមុនពេលគណៈកម្មការហៅឈ្មោះឱ្យចូល
- ប្តូរសន្លឹកកិច្ចការ ឬក្រដាសព្រាងឱ្យគ្នាទៅវិញទៅមក ឬផ្ទៀងផ្ទាត់ចម្លើយ ឬចម្លងគ្នា ឬដាក់សន្លឹកកិច្ចការឆ្ងាយពីមុខរបស់ខ្លួនបង្កឱ្យអ្នកដទៃអាចមើល ឬឆក់យកបានឡើយ
- ធ្វើសញ្ញាសម្គាល់ណាមួយលើសន្លឹកកិច្ចការ
- ជជែក ឬពិភាក្សាគ្នាដែលធ្វើឱ្យរំខានអ្នកដទៃ
- ខ្ចីប៊ិច ខ្មៅដៃ ទឹកលុប ជ័រលុប ឬបន្ទាត់ពីអ្នកដទៃ
- ងើបឈរ ងាកឆ្វេង-ស្តាំ អើតឈ្ងោកទៅមុខ បែរទៅក្រោយ ឬដើរចេញពីកន្លែងអង្គុយដោយគ្មានការអនុញ្ញាតពីអនុរក្ស ក្នុងអំឡុងពេលប្រឡង
- ចេញក្រៅបន្ទប់ប្រឡងក្នុងអំឡុងពេល ៣០ (សាមសិប) នាទីដំបូង គិតចាប់ពីពេលចាប់ផ្តើមធ្វើវិញ្ញាសាសរសេរ លើកលែងតែមានការចាំបាច់ និងទទួលបានការអនុញ្ញាតពីអនុរក្ស
- សរសេរលើសន្លឹកកិច្ចការណាដែលគ្មានហត្ថលេខារបស់គណៈកម្មការ។

**គ. ករណីយឺតយ៉ាវ÷**

- តិចជាង ១៥ (ដប់ប្រាំ) នាទី÷ បេក្ខជនត្រូវស្នើសុំការអនុញ្ញាតពីគណៈកម្មការរៀបចំការប្រឡង
- លើសពី ១៥ (ដប់ប្រាំ) នាទី÷ បេក្ខជនត្រូវស្នើសុំការអនុញ្ញាតពីប្រធានគណៈកម្មការរៀបចំការប្រឡង។

**២. វិធានការ**

**ក. ត្រូវបានពិន្ទុសូន្យករណីបេក្ខជនប្រព្រឹត្តល្មើសដូចខាងក្រោម÷**

- ដើរចុះឡើងចេញពីតុប្រឡងដោយគ្មានការអនុញ្ញាតពីគណៈកម្មការរៀបចំការប្រឡង
- ហែកសន្លឹកកិច្ចការចោល ឬមិនប្រគល់សន្លឹកកិច្ចការជូនគណៈកម្មការរៀបចំការប្រឡង
- ផ្លាស់ប្តូរកន្លែងអង្គុយដោយពុំមានការអនុញ្ញាតជាមុនពីគណៈកម្មការរៀបចំការប្រឡង

NW

- ឱ្យ ឬទទួលសន្លឹកកិច្ចការរបស់ខ្លួនទៅ ឬពីអ្នកដទៃចម្លង បន្ទាប់ពីទទួលការព្រមានពីអនុរក្សចមកហើយ ឱ្យអ្នកដទៃសរសេរលើសន្លឹកកិច្ចការរបស់ខ្លួន ឬជួយសរសេរលើសន្លឹកកិច្ចការរបស់អ្នកដទៃ
- ឱ្យអ្នកដទៃប្រឡងជំនួស
- ធ្វើសញ្ញាសម្គាល់ផ្សេងៗលើសន្លឹកកិច្ចការប្រឡង
- ដណ្តើមយកសន្លឹកកិច្ចការអ្នកដទៃមកចម្លង
- ហែក ឬលាក់សន្លឹកកិច្ចការអ្នកដទៃ ឬយកសន្លឹកកិច្ចការអ្នកដទៃមកធ្វើជាសន្លឹកកិច្ចការរបស់ខ្លួន
- ប្រើប្រាស់ទូរសព្ទ វិទ្យុទាក់ទង កុំព្យូទ័រ ឬសារអេឡិចត្រូនិកគ្រប់ប្រភេទ ដែលប្រើប្រាស់សម្រាប់ទំនាក់ទំនងក្នុងការធ្វើវិញ្ញាសាសរសេរ
- បោះវិញ្ញាសាចេញក្រៅបន្ទប់ប្រឡង ឬចេញទៅយកឯកសារ ឬក្លែងបន្លំឯកសារ ឬយកសំណៅចម្លើយពាក់ព័ន្ធនឹងវិញ្ញាសាចូលក្នុងបន្ទប់ប្រឡងក្នុងពេលកំពុងធ្វើវិញ្ញាសា។

**ខ. ហាមមិនឱ្យប្រឡង ឬត្រូវបានបញ្ឈប់ការប្រឡង និងចាត់ទុកជាមោឃៈចំពោះករណីដូចខាងក្រោម÷**

- ប្រើអំពើហិង្សា ឬបង្កជម្លោះនៅក្នុងបរិវេណនៃមណ្ឌលប្រឡង
- យកអាវុធជាតិផ្ទុះចូលក្នុងបន្ទប់ប្រឡង

**គ.ម.ឆ.** បានបែងចែកបេក្ខជនទៅតាមក្រុម និងកាលបរិច្ឆេទដូចខាងក្រោម÷

- **ក្រុមទី១**
  - **កាលបរិច្ឆេទ:** ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២
  - **ទីកន្លែង:** នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា- កូរ៉េ (CKCC)។
- **ក្រុមទី២**
  - **កាលបរិច្ឆេទ:** ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២
  - **ទីកន្លែង:** នៅសាលប្រជុំជាន់ទី២ នៃអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។
- **ក្រុមទី៣**
  - **កាលបរិច្ឆេទ:** ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២
  - **ទីកន្លែង:** នៅសាលប្រជុំជាន់ទី២ នៃអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**សម្គាល់**÷ ចំពោះកំហុសក្រៅពីករណីដែលបានចែងក្នុងវិធានការខាងលើ នឹងត្រូវបានកំណត់ដោយប្រធានគណៈកម្មការរៀបចំការប្រឡង តាមកំហុសជាក់ស្តែង។

NV